00268688

C26/5/8

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.១៥) |
| **ឈ្មោះរឿងក្តី:** | **ខៀវ សំផន** |
| **ដាក់តម្កល់ជូន:** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទដាក់ឯកសារ:** | ថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ |
| **ភាគីដាក់តម្កល់:** | មេធាវីការពារក្តី |
| **ភាសាដើម:** | ភាសាបារាំង និងបកប្រែក្រៅផ្លូវការជាភាសាខ្មែរ |
| **ប្រភេទឯកសារ:** | **សាធារណៈ** |

---

## ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីចំពោះពាក្យសុំស្នើពន្យារពេល របស់សហព្រះរាជអាជ្ញា

---

**<u>បញ្ជូនដោយ:</u>**

**មេធាវីរបស់លោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGÈS

**<u>ដោយមានជំនួយពី:</u>**

លោកស្រី សេង សុជាតា

កញ្ញា Charlotte MOREAU

**<u>បញ្ជូនទៅ:</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ថុល

លោក ហ្វួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
05 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K. K. Ratanak

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
05 / JAN / 2009
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Try

00268689



C26/518

# ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីចំពោះពាក្យសុំស្នើពន្យាពេល របស់សហព្រះរាជអាជ្ញា

## ក- អង្គហេតុ និងនីតិវិធី

1 នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ សហមេធាវីរបស់លោក ខៀវសំផន បានដាក់ពាក្យបណ្តឹងរបស់ខ្លួនប្រឆាំងនឹងការពន្យាពេលឃុំខ្លួនកូនក្តីរបស់ខ្លួន។ សហព្រះរាជអាជ្ញាបានទទួលឯកសារនេះត្រូវជាភាសាទីពីរដែលគាត់ប្រើក្នុងការងារ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ គឺ២០ថ្ងៃក្រោយ។ នៅក្នុងពាក្យសុំមួយ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានសុំ « អង្គបុរេជំនុំជម្រះផ្តល់មួយសប្តាហ៍បន្ថែមទៀតដើម្បីដាក់នូវចម្លើយតបរបស់ខ្លួន (...) ហើយដោយហេតុនេះ ពន្យាពេលវេលាកំណត់រហូតដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ »។

## ខ- កំណត់សំគាល់

2 ជាគោលការណ៍ ភាគីទាំងឡាយមានរយៈពេល១៥ថ្ងៃដើម្បីដាក់ចម្លើយតបណាមួយចំពោះពាក្យសុំ ឬសារណា (មាត្រា៨.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ)។ ចំណែកឯការឃុំខ្លួនបណ្តោះអាសន្ន អត្ថបទដែលពាក់ព័ន្ធបានដាក់កំហិតឲ្យមានដំណើរការលឿនបំផុត៖ ឧទាហរណ៍ « សាលដីការបស់សភាស៊ើបសួរ ត្រូវសម្រេចចេញនៅក្នុងរយៈពេលដប់ប្រាំថ្ងៃ បន្ទាប់ពីបានទទួលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ» (មាត្រា២៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

3 នៅក្នុងករណីនេះ សារណារបស់ក្រុមការពារក្តីត្រូវបានបកប្រែក្នុងរយៈពេល២០ថ្ងៃក្រោយការដាក់បញ្ជូននៃសារណានេះជាភាសាបារាំង និងភាសាខ្មែរ ហើយនេះបានបណ្តាលឲ្យពន្យាពេលវេលាកំណត់១៥ថ្ងៃដូចបានចែងនៅក្នុងអត្ថបទពាក់ព័ន្ធ។ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថាអនុញ្ញាតឲ្យមានការពន្យាពេលវេលាកំណត់ដូចដែលសហព្រះរាជអាជ្ញាបានសុំនេះ រយៈពេលកំណត់រវាងការបញ្ជូនសារណាដើម និងការបញ្ជូនចំលើយរបស់សហព្រះរាជអាជ្ញា គឺសារុបមានអស់រយៈពេលមួយខែ និងដប់ពីរថ្ងៃ (២០+១៥+៧=៤២ ថ្ងៃ)។ ដូច្នេះ អ្នកដែលខាតបង់ គឺកូនក្តីរបស់ពួកគាត់លោក ខៀវ សំផន ដែលរង់ចាំយ៉ាងអត់ធ្មត់នូវការដោះលែងរូបគាត់។

4 មេធាវីការពារក្តី ជាមួយនឹងសហព្រះរាជអាជ្ញា សំគាល់ថាការយឺតយ៉ាវនេះសំខាន់គឺបណ្តាលមកពីការខ្វះអ្នកបកប្រែ/អ្នកបកប្រែផ្ទាល់មាត់ ហើយមកពីការយឺតយ៉ាវក្នុងការបកប្រែនៃសារណារបស់

00268690



ក្រុមការពារក្តីនេះជាភាសាអង់គ្លេស។

5 ពួកគាត់សូមរំលឹកថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការមួយដែលប៉ះពាល់យ៉ាងខ្លាំងបំផុតដល់សិទ្ធិ និងសិទ្ធិសេរីភាពរបស់លោក ខៀវ សំផន ហើយសូមរំលឹកផងដែរថា វិធានការនេះបង្ខំឲ្យមានការដោះស្រាយជាបន្ទាន់។

6 ដូច្នេះហើយ ពួកគាត់ចាត់ទុកម្តងទៀតថា កង្វះខាតធនធាន និងបុគ្គលិកខាងបកប្រែ ប៉ះពាល់ដល់ផលប្រយោជន៍របស់កូនក្តីរបស់ខ្លួន។

**ដោយហេតុផលទាំងនេះ**

7 សហមេធាវីសូមឲ្យអង្គបុរេជំនុំជម្រះ កត់ត្រាទុកនូវការយឺតយ៉ាវទាំងនេះ ដែលបណ្តាលមកពីកង្វះខាតបុគ្គលិក និងធនធានខាងបកប្រែ។

8 ចំណែកឯបញ្ហាជាក់ស្តែងនៃការពន្យាពេលកំណត់ សហមេធាវីទុកឲ្យតុលាការធ្វើសេចក្តីសម្រេច។

**ក្រោមការរក្សាសិទ្ធិគ្រប់យ៉ាង**

ជំនួសមេធាវីការពារក្តី

លោក ស សូវាន